ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត ស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១**.-

ត្រូវបានបង្កើត ស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម។ ស្ថានបេសកកម្មអចិន្ត្រៃយ៍ មាននិវេសនដ្ឋាន នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

**មាត្រា ២**.-

ស្ថានបេសកកម្មអចិន្ត្រៃយ៍ ត្រូវដឹកនាំដោយប្រធានមួយរូបមានឋានៈជាអគ្គរាជទូត។

**មាត្រា ៣**.-

ស្ថានបេសកកម្មអចិន្ត្រៃយ៍នេះ ត្រូវមានសមាសភាព ដូចជា មន្ត្រីការទូត និងមន្ត្រីបច្ចេកទេសចំនួន ៥ (ប្រាំ) រូប។

**មាត្រា ៤**.-

ស្ថានបេសកកម្មអចិន្ត្រៃយ៍នេះ ត្រូវមានការិយាល័យដោយឡែក និងមានកញ្ចប់ថវិកាស្ថិតក្រោមក្រសួងពាណិជ្ជកម្ម។ ប្រព័ន្ធហិរញ្ញកិច្ចសម្រាប់មន្ត្រីការទូត និងមន្ត្រីបច្ចេកទេស នៃស្ថានបេសកកម្មអចិន្ត្រៃយ៍នេះត្រូវស្ថិតក្នុងប្រភេទ "ក" ។

**មាត្រា ៥**.-

ស្ថានបេសកកម្មអចិន្ត្រៃយ៍នេះ ត្រូវមានភារកិច្ចទទួលបន្ទុកការងារពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចពាណិជ្ជកម្មនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា ដូចជា អង្គការពាណិជ្ជកម្មពិភពលោក សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ និងអង្គការគយពិភពលោក។

**មាត្រា៦**.-

ប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍នេះ ត្រូវធ្វើរបាយការណ៍ការងារជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងចម្លងជូនស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាប្រចាំទីក្រុងហ្សឺណែវ ប្រទេសស្វីស។

**មាត្រា ៧**.-

ស្ថានបេសកកម្មអចិន្ត្រៃយ៍នេះ មានត្រាផ្លូវការសម្រាប់ប្រើប្រាស់ក្នុងការបំពេញការងាររបស់ខ្លួន។

**មាត្រា ៨**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ